រោគខាន់ស្លាក់
រោគតេតាណូស
រោគក្អកមាន់

# ការចាក់ថ្នាំបង្ការរោគ

## តើអ្វីដែលអ្នកត្រូវតែដឹង

### ១ តើហេតុអ្វីបានជា ចាក់ថ្នាំបង្ការរោគ?

**រោគខាន់ស្លាក់ រោគតេតាណូស រោគក្អកមាន់ ជាជម្ងឺដ៏ធ្ងន់មួយ ដែលកើតឡើងដោយសារមេរោគ។** រោគខាន់ស្លាក់ រោគក្អកមាន់ ឆ្លងពីមួយទៅមួយ។ រីឯរោគតេតាណូស វាជ្រាបចូលក្នុងខ្លួនដោយតាមការមុត កាត់ឬដំបៅរបួស។

**រោគខាន់ស្លាក់** កើតឡើងដោយមានអ្វីមួយក្រាសបិតនៅក្នុងក ខាងក្រោយ។

- វាអាចធ្វើឲ្យមានការពិបាកដកដង្ហើម កំរើកលែងបាន គាំងបេះដូង ហើយអាចមានទៅដល់ស្លាប់។

**រោគតេតាណូស(ជម្ងឺរឹងថ្គាម)**ដែលធ្វើឲ្យសាច់ដុំតឹង ឈឺចុកចាប់ ពេញខ្លួនតាមធម្មតា។

- វាអាចធ្វើឲ្យថ្គាមរឹង ហើយអ្នកជម្ងឺមិនអាចបើកមាត់ ឬលេបរួច។ រោគ តេតាណូស អាចធ្វើឲ្យយើងស្លាប់ ក្នុងមួយភាគដប់តាមរឿងដឹងពីមុនមក។

**រោគក្អកមាន់(ក្អកមាន់)** ក្អកខ្លាំងមានរយះវា ធ្វើឲ្យទារក មិនញាំុ មិនផឹក ឬ មិនដកដង្ហើម។ រយះវាក្អករហូតទៅដល់រាប់អាទិត្យ។

- វាអាចធ្វើឲ្យហើមសួត ប្រកាច់ (ញាក់ ហើយវាមានពេលវា) ខូចខួរក្បាលនឹងស្លាប់។

**ការចាក់ថ្នាំបង្ការ រោគខាន់ស្លាក់ រោគតេតាណូស រោគក្អកមាន់ ហៅថា (ឌីធីអេភី) អាចជួយការពារជម្ងឺនេះ។** (ឌីធីអេភី) គឺថ្នាំចាក់ការពារសំរាប់ក្មេងក្នុងវ័យកុមារភាព។ ក្មេងៗជាច្រើននិងកើតជម្ងឺនេះបើឈប់ចាក់ថ្នាំការពារវា។

(ដីធីអេភី) គឺជាថ្នាំចាក់ការពារថ្មីដោយគ្មានគ្រោះថ្នាក់។ ថ្នាំចាក់ការពារពីមុន ហៅថាឌីធីភី។ ថ្នាំចាក់ ឌីធីភីឥឡូវគេឈប់ប្រើវាក្នុងប្រទេសអាមេរិកហើយ។

### ២ តើនរណាគួរចាក់ថ្នាំការពារ ឌីធីអេភី ហើយត្រូវពេលណា?

**កូនក្មេង** ត្រូវចាក់ថ្នាំ ឌីធីអេភី ការពារ ៥ដង ចាក់ថ្នាំមួយដងៗ តាមអាយុខាងក្រោមនេះ :

✓ ២ខែ ✓ ៤ខែ ✓ ៦ខែ

✓ ១៥-១៨ខែ ✓ ៤-៦ ឆ្នាំ

ថ្នាំ ឌីធីអេភី អាចចាក់ក្នុងពេលជាមួយគ្នាជាមួយថ្នាំការពា រផ្សេងៗទៀត។

### ៣ ចំពោះក្មេងខ្លះមិនគួរចាក់ថ្នាំ ឌីធីអេភី ការពារទេ គួរតែត្រូវរងចាំ

- ក្មេងដែលឈឺតិចៗ មានជម្ងឺផ្ដាសាយតិចៗ អាចចាក់ថ្នាំការពារវា។ តែបើក្មេងៗណាមានជម្ងឺខ្លាំងៗ ត្រូវតែចាំ រហូតទាល់តែជា ទើបអាចចាក់ថ្នាំ ឌីធីអេភី ការពារវាបាន។

- ចំពោះក្មេងខ្លះណា ដែលបានចាក់ថ្នាំ ឌីធីអេភីការពារបានម្ដង ហើយវាធ្វើទុក្ខខ្លាំងដល់ជីវិត គឺមិនគួរចាក់ វាម្ដងទៀតទេ។

- ចំពោះក្មេងខ្លះណា មានជម្ងឺខាងខួរក្បាល ឬខាងសសៃប្រសាទ បន្ទាប់ពីបានចាក់ ឌីធីអេភី ប្រាំពីរថ្ងៃមក គឺមិនគួរចាក់ វាម្ដងទៀតទេ។

- និយាយជាមួយដុកទ័រ បើកូនរបស់អ្នក :
  - មានជម្ងឺប្រកាច់ ឬ ដួល បន្ទាប់ពីបានចាក់ថ្នាំ ឌីធីអេភី បានម្ដង
  - យំមិនឈប់ ក្នុងរយះពេលបីម៉ោង ឬច្រើនជាងហ្នឹងទៀត បន្ទាប់ ពីបាន ចាក់ថ្នាំ ឌីធីអេភី រួច។
  - បើមានគ្រុនក្ដៅលើសពី ១០៥° បន្ទាប់ពីចាក់ថ្នាំ ឌីធីអេភី រួច។

សូមសួរអ្នកមើលថែរក្សាសុខភាពបើចង់ដឹងដំណឹងបន្ថែមទៀត។ កូនក្មេងខ្លះ មិនអាចចាក់ថ្នាំការពាររោគក្អកមាន់។ ត្រូវតែចាក់ថ្នាំការពារ ដែលមិនសំរាប់ ការពាររោគក្អកមាន់ ហៅថា ឌីធី។

### ៤ ក្មេងជំទង់ ហើយនឹងមនុស្សពេញវ័យ

ថ្នាំចាក់ការពារ ឌីធីអេភី បានសំរាប់តែក្មេងអាយុក្រោម ៧ ឆ្នាំ។ គេមិនចាក់ ការពាររោគក្អកមាន់ទៅក្មេងដែលអាយុពី ៧ ឆ្នាំឡើងទៅទេ។

តែក្មេងជំទង់ និងពេញវ័យ ត្រូវចាក់ថ្នាំការពាររោគ តេតាណូស និងរោគ ខាន់ស្លាក់។ ថ្នាំចាក់បង្ការរោគបន្ថែមនេះ ហៅថា ធីឌី គេតែងតែចាក់ឲ្យក្មេង ពី ១១-១២ ឆ្នាំ ហើយបន្ទាប់មកទៀត ១០ ឆ្នាំម្ដង។ មានក្រដាសសំរាប់មើល ថ្នាំចាក់ការពារ ធីឌី ដែលមិនចូលគ្នានេះ។

## ៥ បើចាក់ថ្នាំការពារ ឌីធីអេភី តើអាចមាន គ្រោះថ្នាក់អ្វីកើតឡើង?

បើមាន រោគខាន់ស្លាក់ រោគតេតាណូស រោគក្អកមាន់ហើយ វាអាចមាន គ្រោះថ្នាក់ជាង ចាក់ថ្នាំការពារ ឌីធីអេភី ទៀត។

តែទោះបីយ៉ាងណាក៏ដោយ ថ្នាំចាក់ការពារ ក៏វាអាចមានបញ្ហា រខ្លាំងខ្លះដែរ ដូចជា ការប្រែប្រួលក្នុងខ្លួនយើងមិនអាចទទួលបាន។ មនុស្សភាគតិច ណាស់ដែលអាចមានឈឺឬ មានគ្រោះថ្នាក់ដល់ស្លាប់ បើចាក់បង្ការវា។

**បញ្ហាតិចៗដែលអាចកើតឡើង (ជាទូទៅ)**
- គ្រុនក្តៅ (ចំពោះក្មេង ប្រហែល មាន ១ ក្នុង ៤ អ្នក)
- ក្រហម ឬ ហើមទៅ កន្លែងចាក់ថ្នាំ(ចំពោះក្មេង ប្រហែលមាន ១ ក្នុង ក្មេង ៤ អ្នក)
- ឈឺចុក ដែលឆាប់ឈឺ នៅកន្លែងចាក់ថ្នាំ (ចំពោះក្មេង ប្រហែលមាន ១ ក្នុង ក្មេង ៤ អ្នក)

បញ្ហាពួកនេះតែងតែកើតឡើង នៅពេល ចាក់ថ្នាំទៅលើកទី ៤ និង ទី ៥ បន្ទាប់ពី ចាក់ ឌីធីអេភី ពីមុនៗមក។ ជួនការ ចាក់ថ្នាំទៅលើកទី ៤ និង ទី ៥ វាអាចធ្វើឲ្យហើមពេញដៃ ឬ ជើង នៅកន្លែងចាក់ម្ជុល ពី ១ ថ្ងៃ ទៅ ៧ ថ្ងៃ (ចំពោះក្មេង ប្រហែល មាន ១ ក្នុង ក្មេង ៣០ អ្នក)។

**បញ្ហាតិចៗដែលអាចកើតឡើងផ្សេងៗទៀត ដូចជា :**
- មួម៉ៅច្រើន(ចំពោះក្មេង ប្រហែល មាន ១ ក្នុង ក្មេង ៣ អ្នក)
- ហត់ ឬ ញាំុអត់បាន(ចំពោះក្មេង ប្រហែល មាន ១ ក្នុង ក្មេង ១០ អ្នក)
- ក្អួត(ចំពោះក្មេង ប្រហែល មាន ១ ក្នុង ក្មេង ៥០ អ្នក)

បញ្ហាពួកនេះ តាមធម្មតាកើតឡើង ពេលបានចាក់ថ្នាំ ពី ១-៣ ថ្ងៃ រួច។

**បញ្ហាឈឺល្មមៗដែរ (មិនទូរទៅ)**
- ប្រកាច់(ញាក់ ឬ ចាប់ផ្តើម)(ប្រហែល មានក្មេង ១ ក្នុង ក្មេង ១៤,០០០អ្នក)
- យំ មិន ចេះបាត់ អស់រយៈពេល ពី ៣ ម៉ោងឡើងទៅ (ប្រហែល មាន ក្មេង ១ ក្នុងក្មេង ១,០០០ អ្នក)
- គ្រុនក្តៅខ្លាំង លើសពី ១០៥° (ប្រហែលមានក្មេង ១ ក្នុងក្មេង ១៦,០០០ អ្នក)

**បញ្ហាខ្លាំងមែនទែន (តែកម្រមាន)**
- គឺមានការទាស់ប្រឆាំងនឹងថ្នាំយ៉ាងខ្លាំង (មានតិចជាង ១ ក្នុង មួយលានអ្នក)
- មានបញ្ហាជាច្រើន ដ៏ខ្លាំងទៀតកើតឡើង បន្ទាប់ពីចាក់ថ្នាំការពារ ឌីធីភី រួចដូចជា :
  - ប្រកាច់ យ៉ាងយូរ ដំណើរភ្លឹក ឬ ដឹងខ្លួនតិចៗ
  - ខួរក្បាលខូចខ្ទេចខ្ទីរហូត

ពួកនេះវាកម្រមានកើតឡើងហើយ ពិបាកនិយាយថាវាកើតឡើងមក ដោយសារការចាក់ថ្នាំការពារនោះ ឬយ៉ាងណាទេ។

---

ការពារកុំឲ្យមានគ្រុនក្តៅ គឺវាសំខាន់ណាស់ចំពោះក្មេងដែលមានជម្ងឺរោគប្រកាច់ ឬសំរាប់រឿងអ្វីក៏ដោយ។ ហើយវាសំខាន់ណាស់បើដឹងក្រុមគ្រួសារណាមាន រោគប្រកាច់។ យើងអាចបន្ថយកុំឲ្យមានគ្រុនក្តៅដោយឲ្យថ្នាំ អាស្ពីរីន-ហ្វ្រី ជួយរំដោះខ្លះពេលដែលបានចាក់ថ្នាំរួច ក្នុងរយៈ ២៤ ម៉ោង។ សូមមើលក្រដាសដែលគេឲ្យ មួយសំណុំដើម្បីបង្ហាត់បង្រៀនដូចតទៅ។

## ៦ តើអ្វីទៅ ដែលអាចធ្វើដំណើរប្រែប្រួលខ្លាំង ឬ តិចនៅក្នុងខ្លួន?

**តើខ្ញុំត្រូវកត់សំគាល់អ្វី?**

លក្ខណខ្លះ ដែលមិនធម្មតាហើយមាន ការប្រែប្រួលខ្លាំង ដូចជាគ្រុនក្តៅខ្លាំង ឬ ចរិកមិនធម្មតា។ វាកម្រមានការប្រែប្រួលខ្លាំង ពេលចាក់ថ្នាំរួច។ បើសិនជាមាន វានឹងកើតឡើងក្នុងរយៈ ពេល ពីពីរនាទី ទៅពីរបីម៉ោង បន្ទាប់ពីចាក់ថ្នាំរួច។ វាឲ្យសញ្ញាដូចជា ពិបាកដកដង្ហើម ស្អក ដកដង្ហើមសូរគ្រេតគ្រេត ស្លាំង ខ្សោយ បេះដូងដើរលឿន វិលមុខ។ បើប្រសិនជាមានគ្រុនក្តៅ ឬ រោគប្រកាច់ វាត្រូវតែកើតឡើង នៅក្នុងរយៈមួយអាទិត្យបន្ទាប់ ពីចាក់ថ្នាំរួច។

**តើខ្ញុំនឹងគួរធ្វើដូចម្តេច?**
- ទូរស័ព្ទទៅដុកទ័រ ឬ ឲ្យនរណាជូនទៅដុកទ័រភ្លាមៗ។
- ប្រាប់ដុកទ័រ អ្វីដែលប្រែប្រួល ថ្ងៃណា ពេលណាដែលកើតបន្ទាប់ ពីចាក់ថ្នាំរួច។
- សុំស្នើរដុកទ័រ អាំងហ្វីមីញេរ ឬកន្លែងថែរក្សារខាងសុខភាព កត់ទុកក្នុងបញ្ជី រាយការណ៏នូវពេលចាក់ថ្នាំការពារមានការប្រែប្រួលក្នុងខ្លួនហៅថា(វីអេអ៊ីអរអេស) ឬ ទូរស័ព្ទ **១-៨០០-៨២២-៧៩៦៧**។

## ៧ ការចាក់ថ្នាំការពាររបួស ប្រជាជាតិ ហើយគេមានវិធីការសងវិញ

អ្នកកម្រមានព្រឹត្តិការណ៏ ឬ បើកូនអ្នកបានការប្រែប្រួលខ្លាំងពេលចាក់ ថ្នាំការពាររួច វិធីខាងសហព័ន្ធនឹងជួយចេញប្រាក់ទៅអ្នកដែលមានគ្រោះថ្នាក់។

បើចង់ដឹងដំណឹងសព្វគ្រប់ទៀត ពីរឿងការសង ក្រោយពីការចាក់ថ្នាំការពារ របួសប្រជាជាតិ សូមទូរស័ព្ទ ១-៨០០-៣៣៨-២៣៨២ ឬ ប្រើ វិបសៃ **http://www.hrsa.gov/osp/vicp/**

## ៨ តើខ្ញុំអាចរៀនថែមទៀតតាមរបៀបណា?

- សួរកន្លែងអ្នកទៅមើលថែរក្សារសុខភាព។ គេអាចឲ្យបញ្ជីមើលពីលទ្ធផលពីចាក់ ថ្នាំការពារ ហើយដំណឹងផ្សេងៗ ហើយនិងកន្លែងរបស់វា។
- ទូរស័ព្ទទៅកន្លែងថែរក្សារសុខភាពសំរាប់ធ្វើឲ្យសាំងរោគ របស់រដ្ឋ ដែលនៅ ជិតផ្ទះអ្នក។
- ទូរស័ព្ទទៅកន្លែងការពារ និងបញ្ឈប់កុំឲ្យមានរោគ ហៅថា (ស៊ីឌីស៊ី)
  - Call 1-800-232-4636 (1-800-CDC-INFO)
  - ឆែកមើល វិបសៃ ខាងវិធីធ្វើឲ្យសាំងនឹងរោគ **http://www.cdc.gov/nip**

CDC
CENTERS FOR DISEASE CONTROL AND PREVENTION

**U.S. DEPARTMENT OF HEALTH & HUMAN SERVICES**
Centers for Disease Control and Prevention
National Immunization Program

Vaccine Information Statement
DTaP (7/30/01) - Cambodian 42 U.S.C. § 300aa-26

Translation provided by Minnesota Department of Health